# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

លេខ៖ 51 PR-17/EoJ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧

## <u>ជប៉ុនផ្តល់ថវិកាសរុបចំនួន ៣២៩,៧៣៦ដុល្លារអាមេរិក</u>
## <u>សម្រាប់ការជួសជុលផ្លូវ និងការកែលម្អមណ្ឌលសុខភាព</u>

រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន ៣២៩,៧៣៦ ដុល្លារអាមេរិក ដល់ស្ថាប័នចំនួន៤ ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបួន សម្រាប់គម្រោងដូចតទៅ៖

**១. <u>គម្រោងជួសជុលផ្លូវ១ខ្សែ ក្នុងឃុំរមទម ស្រុករវៀង ខេត្តព្រះវិហារ (ថវិកាចំនួន ៨៧,៥៨៧ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ</u>

គម្រោងនេះ នឹងធ្វើការជួសជុលផ្លូវមួយខ្សែ ក្នុងឃុំរមទម ស្រុករវៀង ខេត្តព្រះវិហារ ដែលត្រូវបានរងការខូចខាតដោយគ្រោះទឹកជំនន់កាលពីខែកក្កដា ឆ្នាំ២០១៧ កន្លងទៅថ្មីៗនេះ។ ជាមួយនឹងគម្រោងនេះ ប្រជាពលរដ្ឋប្រមាណជា ២,៣០០នាក់ នឹងអាចធ្វើដំណើរដោយសុវត្ថិភាពទៅកាន់សាលារៀន ផ្សារ និងមណ្ឌលសុខភាព ហើយផ្លូវនេះនឹងរួមចំណែកក្នុងការដឹកជញ្ជូនកសិផលផងដែរ។

**២. <u>គម្រោងសាងសង់អគារមណ្ឌលសុខភាពក្រញូងសែនជ័យ ខេត្តក្រចេះ (ថវិកាចំនួន ៨៩,៦៣២ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរសុខាភិបាលខេត្តក្រចេះ</u>

គម្រោងនេះ នឹងសាងសង់អគារមណ្ឌលសុខភាពថ្មី១ខ្នងមាន២ជាន់ ក្នុងឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ។ ជាមួយនឹងគម្រោងនេះ ប្រជាពលរដ្ឋប្រមាណជា ១៣,៨០០នាក់ នឹងទទួលបានសេវាសុខភាពជាមូលដ្ឋានកាន់តែប្រសើរជាងមុនដូចជា៖ ការសម្រាលកូន ការថែទាំក្រោយសម្រាលកូន និងការចេញវេជ្ជបញ្ជាថ្នាំពេទ្យ ដែលបច្ចុប្បន្ន ប៉ុស្តិ៍សុខភាព មិនអាចផ្តល់ជូនបាន។

**៣ .<u>គម្រោងសាងសង់អគារមណ្ឌលសុខភាពបារ៉ាំង ក្នុងខេត្តកណ្ដាល (ថវិកាចំនួន ៨៤,៩៧២ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិល្វាឯម ខេត្តកណ្ដាល</u>

គម្រោងនេះ នឹងសាងសង់អគារមណ្ឌលសុខភាពថ្មីមួយខ្នង នៅមណ្ឌលសុខភាពបារ៉ាំង ក្នុងស្រុកល្វាឯម ខេត្តកណ្ដាល ដែលបច្ចុប្បន្នមានតែមួយអគារ៤បន្ទប់ប៉ុណ្ណោះសម្រាប់ដំណើរការ។ ជាមួយនឹងគម្រោងនេះ ប្រជាពលរដ្ឋប្រមាណជា ៥,២០០នាក់ នឹងទទួលបាននូវអគារមណ្ឌលសុខភាពថ្មីដែលស្របតាមស្តង់ដារក្រសួងសុខាភិបាល និងទទួលបាននូវសេវាសុខភាពកាន់តែល្អប្រសើរជាងមុន។

**៤. <u>គម្រោងបំពាក់ម៉ាស៊ីនកាំរស្មីអ៊ិច និងម៉ាស៊ីនឆ្លុះអេកូ នៅមន្ទីរពេទ្យកុមារអង្គរ ក្នុងខេត្តសៀមរាប (ថវិកាចំនួន ៦៧,៥៤៥ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរពេទ្យកុមារអង្គរ</u>

គម្រោងនេះ នឹងបំពាក់នូវម៉ាស៊ីនកាំរស្មីអ៊ិច និងម៉ាស៊ីនឆ្លុះអេកូជាឈុត នៅមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប។ ជាមួយនឹងគម្រោងនេះ កុមារប្រមាណជា ៧,២០០នាក់ នឹងត្រូវបានពិនិត្យជម្ងឺដោយការប្រើប្រាស់ម៉ាស៊ីនកាំរស្មីអ៊ិចនេះ ហើយកុមារប្រមាណជា ៣,០០០នាក់ ក៏នឹងត្រូវបានត្រួតពិនិត្យតាមដានជម្ងឺដោយការប្រើប្រាស់ម៉ាស៊ីនឆ្លុះអេកូនេះ ជារៀងរាល់ឆ្នាំផងដែរ។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្ដើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្ថាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា៖ ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុន បានផ្ដល់ថវិកាជាង ៥៧លានដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៨០ គម្រោងនៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*